# សង្ខេបព្រឹត្តិការណ៍សង្គាយនានៃធម៌វិន័យក្នុងពុទ្ធសាសនាទាំង៦លើក

*ដោយ ភិក្ខុ **សឿង វុទ្ធី*** (M.A,Bdh,ITBMU)

## I. **បឋមសង្គាយនា** ( សង្គាយនាលើកទី១ )

1. **ថ្ងៃ-ខែ-ឆ្នាំ** : ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅបាន**៣**ខែ គឺមុន គ.ស **៥៤៣**ឆ្នាំ។
2. **ទីកន្លែង** : គុហាសត្តបន្នី ភ្នំវេភារៈ ក្រុងរាជគ្រឹះ ប្រទេសឥណ្ឌា។
3. **ក្រោមអធិបតីភាព** : ព្រះមហាកស្សបត្ថេរ។
4. **ចំនួនអ្នកចូលរួម** : ព្រះអរហត្តដែលបានបដិសម្ភិទាញាណចំនួន **៥00**អង្គ។
5. **អ្នកឧបត្ថម្ភ** : ស្តេចអជាតសត្តុ ព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារ។
6. **មូលហេតុ** : ភិក្ខុ**សុភទ្ទ**ពោលពាក្យមិនគប្បីបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅបាន **៣**ខែ។
7. **គោលបំណង** : ដើម្បីរក្សាធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធឱ្យស្ថិតនៅបរិសុទ្ធតាមទ្រង់ទ្រាយដើម។
8. **រយៈពេល** : ធ្វើឡើងអស់រយៈពេល **៧**ខែ។
9. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី១** : ព្រះមហាឧបាលីសូត្រវិន័យបិដក ព្រះអានន្ទសូត្រព្រះធម៌ និងព្រះអភិធម្មបិដក។

II. **ទុតិយសង្គាយនា** (សង្គាយនាលើកទី២)

1. **ថ្ងៃ-ខែ-ឆ្នាំ** : ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅបាន១០០ឆ្នាំ គឺមុន គ.ស ៤៤៣ឆ្នាំ។
2. **ទីកន្លែង** : វត្តវាលុការាម ទីក្រុងវេសាលី ប្រទេសឥណ្ឌា។
3. **ក្រោមអធិបតីភាព** : ព្រះមហាសព្វកាមិ, ព្រះយស, ព្រះរេវតៈ និងព្រះអជិត មហាថេរ។
4. **ចំនួនអ្នកចូលរួម** : ព្រះអរហត្តដែលបានសម្រេចបដិសម្ភិទាញាណចំនួន ៧០០អង្គ។
5. **អ្នកឧបត្ថម្ភ** : ស្តេចកាលាសោក នៃប្រទេសឥណ្ឌា។
6. **មូលហេតុ** : បណ្តាលមកពីទំនាស់វត្ថុ១០ប្រការ របស់ពួកវជ្ជីភិក្ខុ ដែលផ្សព្វផ្សាយនូវធម៌វិន័យមិនត្រូវតាមអ្វីដែលព្រះពុទ្ធបានបញ្ញត្ត។
7. **គោលបំណង** : ដើម្បីរក្សាច្បាប់វិន័យឱ្យនៅបរិសុទ្ធ ដូចដែលបានបញ្ញត្តដោយព្រះពុទ្ធ។
8. **រយៈពេល** : ធ្វើឡើងអស់រយៈពេល ៨ខែ។
9. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី២** : ព្រះសង្ឃបានបែកជា២ក្រុមគឺៈ **ថេរវាទ** និង**មហាសង្ឃិកៈ**។

III. **តតិយសង្គាយនា** ( សង្គាយនាលើកទី៣ )

1. **ថ្ងៃ-ខែ-ឆ្នាំ** : ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅបាន**២៥០**ឆ្នាំ គឺមុន គ.ស **២៩៣**ឆ្នាំ។
2. **ទីកន្លែង** : វត្តអសោការាម ទីក្រុងបាដលីបុត្ត ប្រទេសឥណ្ឌា។
3. **ក្រោមអធិបតីភាព** : ព្រះមហាមោគ្គលីបុត្តិស្សត្ថេរ។
4. **ចំនួនអ្នកចូលរួម** : ព្រះអរហត្តដែលបានសម្រេចបដិសម្ភិទាញ្ញាណចំនួន **១000**អង្គ។
5. **អ្នកឧបត្ថម្ភ** : ស្តេច**ធម្មាសោក** នៃប្រទេសឥណ្ឌា។
6. **មូលហេតុ** : បណ្តាលមកពីការកើតឡើងនូវព្រះសង្ឃក្លែងក្លាយ និងពាហិរិកទិដ្ឋិ។
7. **គោលបំណង** : ដើម្បីកម្ចាត់ព្រះសង្ឃក្លែងក្លាយ និងដើម្បីរក្សាទុកនូវព្រះសង្ឃដែលល្អបរិសុទ្ធ។
8. **រយៈពេល** : ធ្វើឡើងអស់រយៈពេល **៩**ខែ។
9. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី៣** : ព្រះសង្ឃក្លែងក្លាយចំនួន **៦0,000**អង្គ ត្រូវបានបណ្តេញចេញពីសង្ឃ ហើយសង្ឃទូត ៩ក្រុមត្រូវបានបញ្ជូនទៅកាន់ប្រទេសផ្សេងៗ ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា។

IV. **ចតុត្ថសង្គាយនា** (សង្គាយនាលើកទី៤)

1. **ថ្ងៃ-ខែ-ឆ្នាំ** : ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅបាន**៤៥០**ឆ្នាំ គឺមុន គ.ស **៩៣**ឆ្នាំ។
2. **ទីកន្លែង** : **អនុលេនគុហា** (ឯកសារខ្លះថា នៅ**អាលោកគុហា** អលុវិហារមតឡេ(ស្រុក **មាលាយ**), ប្រទេសស្រីលង្កា។
3. **ក្រោមអធិបតីភាព** : ព្រះមហារក្ខិតត្ថេរ។
4. **ចំនួនអ្នកចូលរួម** : ព្រះអរហត្តចំនួន **៥០០**អង្គ។
5. **អ្នកឧបត្ថម្ភ** : ស្តេចវដ្តគាមិនីអភ័យ នៃប្រទេសស្រីលង្កា។
6. **មូលហេតុ** : បណ្តាលមកពីការកើតឡើងផ្នែកសម្ភារៈនិយម និងការធ្លាក់ចុះផ្នែកសីលធម៌ ដោយសារសង្គ្រាម និងស្តេចអភិភាព។
7. **គោលបំណង** : ដើម្បីសូត្រ និងចារព្រះត្រៃបិដកជាលាយល័ក្ខណ៍អក្សរ និងដើម្បីរក្សាការពារទុកកុំឱ្យមានការបំផ្លិចបំផ្លាញ ដោយប្រការផ្សេងៗ មានសង្គ្រាមជាដើម។ល។
8. **រយៈពេល** : ធ្វើឡើងអស់រយៈពេល **១**ឆ្នាំ។
9. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី៤** : ព្រះត្រៃបិដកត្រូវបានចារលើសស្លាស្លឹករឹតជាលើកដំបូង។ ឯព្រះរាជាបានថតចម្លងត្រៃបិដកទាំងនោះជាច្រើនច្បាប់ ហើយចែកទូទាំងប្រទេស។

V. **បញ្ចមសង្គាយនា** (សង្គាយនាលើកទី៥)

1. **ថ្ងៃ-ខែ-ឆ្នាំ**: ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានបាន **២៤១៤**ឆ្នាំ គឺក្នុង គ.ស**១៨៧១**។
2. **ទីកន្លែង** : នៅវត្តទក្ខិណារាម ទីក្រុងមណ្ឌលេ ប្រទេសភូមា។
3. **ក្រោមអធិបតីភាព** : ព្រះមហាថេរ ជាគរាភិវង្ស:, នរេន្ទ្រាភិធជ:និងសុមង្គលសាមី។
4. **ចំនួនអ្នកចូលរួម** : ព្រះមហាថេរ ជាពហុសូត្រចំនួន **២៤០០**អង្គ។
5. **អ្នកឧបត្ថម្ភ** : ស្តេច **មីនដុន** នៃប្រទេសភូមា ។
6. **មូលហេតុ និងគោលបំណង** : ដើម្បីរៀបចំការបោះពុម្ពជាទ្រង់ទ្រាយព្រះត្រៃបិដក ហើយចារទុកលើផ្ទាំងថ្មម៉ាប(ថ្លើមថ្ម)។
7. **រយៈពេល** : ធ្វើឡើងអស់រយៈពេល **៥**ខែ។
8. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី៥** : គម្ពីរព្រះត្រៃបិដក និងអដ្ឋកថា ត្រូវបានចារឹកលើកផ្ទាំងថ្មចំនួន **៧២៩**ផ្ទាំង (អដ្ឋកថា **៥០០**ផ្ទាំង និងព្រះត្រៃបិដក **២២៩**ផ្ទាំង) ហើយត្រូវបានតម្កល់ទុកក្នុងធម្មចេតិយជាច្រើន។

VI. **ឆដ្ឋសង្គាយនា** (សង្គាយនាលើកទី៦)

1. **ថ្ងៃ-ខែ-ឆ្នាំ** : ធ្វើឡើងបន្ទាប់ពីព្រះពុទ្ធបរិនិព្វានបាន **២៥០០**ឆ្នាំ គឺក្នុងគ.ស **១៩៥៤-៥៦**។
2. **ទីកន្លែង** : **មហាបាសាណគុហា**, នៅ**កាបាអេ**,ទីក្រុងយាំងហ្គូន(រង្គូន), ប្រទេសមីយ៉ាន់ម៉ា(ភូមា)។
3. **ក្រោមអធិបតីភាព** : ព្រះមហារេវតត្ថេរ។
4. **ចំនួនអ្នកចូលរួម** : ព្រះមហាថេរជាពហុស្សូតចំនួន **២៥០០**អង្គ។
5. **អ្នកឧបត្ថម្ភ** : រដ្ឋាភិបាលប្រទេសភូមា គឺលោកនាយករដ្ឋមន្ត្រី **អ៊ុនុ** និងប្រធានាធិបតីគឺលោក **ស៉រ ស្វេ តៃក**។
6. **បុព្វហេតុ និងគោលបំណង** : ដើម្បីធ្វើឱ្យព្រះធម៌តាំងនៅត្រឹមត្រូវតាមច្បាប់ដើម និងដើម្បីផ្សព្វផ្សាយព្រះធម៌ទាំងឡាយនោះ ទូទាំងសកលលោក។
7. **រយៈពេល** : ធ្វើឡើងអស់រយៈពេល **២** ឆ្នាំ។
8. **ព្រឹត្តិការណ៍សំខាន់ក្នុងសង្គាយនាលើកទី៦** : មានព្រះសង្ឃអ្នកចូលរួមមកពីប្រទេសៈ កម្ពុជា ថៃ ឡាវ ស្រីលង្កា និងឥណ្ឌា។ល។

**<u>ចប់ដោយសង្ខេប</u>**

ថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ២០២២

ទីក្រុងសាន់ហូហ្សេ រដ្ឋកាលីហ្វ័ញ៉ា USA